# ការថែទាំកុមារ និងក្មេងជំទង់ ដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ឬហិង្សាផ្លូវភេទ

**ប្រសិនបើអ្នកជាឪពុកម្ដាយ ឬអាណាព្យាបាល ឬអ្នកមើលថែទាំកុមារ ហើយកំពុងអានសេចក្ដីណែនាំនេះដោយសារតែកូនរបស់អ្នកបាន ឬកំពុងរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ឬហិង្សាផ្លូវភេទ នោះមានន័យថាអ្នកបានសម្រេចចិត្តត្រឹមត្រូវហើយ ក្នុងការស្វែងរកជំនួយសម្រាប់កូនរបស់អ្នក ។ ការជួយគាំទ្រដល់កុមារ ដែលកំពុងឆ្លងកាត់បទពិសោធន៍ដ៏ឈឺចាប់ គឺជារឿងដ៏ស្មុគស្មាញមួយ ហើយអ្នកមិនគួរប្រឈមមុខនឹងបញ្ហានេះតែម្នាក់ឯងនោះទេ ។**

កុមារ និងក្មេងជំទង់ ដែលធ្លាប់រងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬហិង្សាផ្លូវភេទ ត្រូវតែទទួលបានការការពារពីការគំរាមកំហែងផ្សេងៗ ។ ពួកគេត្រូវការការជួយគាំទ្រពីអ្នក នៅពេលដែលពួកគេកំពុងតែព្យាយាមព្យាបាលផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ ។

ច្បាប់ជាតិ បានផ្ដល់ការការពារប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងហិង្សាផ្លូវភេទផងដែរ ។ ព័ត៌មានខាងក្រោមនេះ អាចជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកមើលថែទាំកុមារផ្សេងៗទៀត ក្នុងការផ្ដល់ការគាំទ្រកុមារដែលរងគ្រោះដោយអំពើរំលោភបំពានទាំងនោះ ។

**គ្មាននរណាម្នាក់គួរតែរស់នៅក្នុងភាពភ័យខ្លាចនៃអំពើហិង្សាឡើយ**
**ការគាំទ្រពិតជាមាន**

លីកាដូ
LICADHO

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការប្រឹក្សាផ្លូវច្បាប់ អំពីសុវត្ថិភាព និងការគាំទ្រផ្សេងៗទៀត សម្រាប់អ្នក និងកូនរបស់អ្នក សូមទាក់ទងមកកាន់ **អង្គការលីកាដូ** តាមរយៈគេហទំព័រ
**សុវត្ថិភាព និង យុត្តិធម៌**
www.licadho-cambodia.org/safety-and-justice

# ជំហានទី១ ត្រូវជឿលើអ្វីដែលកុមារ ឬក្មេងជំទង់ប្រាប់អ្នក

**អំពើហិង្សាក្នុងគ្រួសារ និងហិង្សាផ្លូវភេទ អាចកើតឡើងចំពោះកុមារគ្រប់រូប មិនថាពួកគេមានអាយុប៉ុន្មាន ឬមានយេនឌ័រអ្វីនោះទេ ។ មិនថាជាក្មេងប្រុស ឬក្មេងស្រី ឬក្មេងមានយេនឌ័រចម្រុះនោះទេ ក្មេងតូច ឬក្មេងជំទង់ដែលមានអាយុរហូត ១៨ឆ្នាំ សុទ្ធតែអាចក្លាយជាជនរងគ្រោះនៃអំពើរំលោភបំពាន ។**

វាអាចជារឿងមួយដែលពិបាក សម្រាប់កុមារក្នុងការប្រាប់រឿងរ៉ាវដែលបានកើតឡើងចំពោះពួកគេទៅនរណាម្នាក់ ហើយវាជារឿងដ៏កម្រដែលកុមារនិយាយកុហកអំពីរឿងរ៉ាវដែលពួកគេទទួលរងនូវការរំលោភបំពាន ។ កុមារខ្លះ អាចប្រាប់រឿងរ៉ាវដ៏ច្រើនដល់អ្នក ហើយកុមារខ្លះទៀត អាចប្រាប់រឿងរ៉ាវតិចតួចបំផុត ហើយវាជារឿងធម្មតា ប្រសិនបើការប្រាប់របស់ពួកគេមានលក្ខណៈមិនសូវច្បាស់លាស់ ឬមិនពេញលេញ ។ ប៉ុន្តែវាជារឿងសំខាន់ណាស់ ដែលអ្នកត្រូវតែជឿជាក់លើកុមារ ។



## កុមារភាគច្រើនតែងតែស្ងៀមស្ងាត់រយៈពេលយូរ ព្រោះតែពួកគេ៖

- មានអារម្មណ៍ភ័យខ្លាច ខ្មាសអៀន ឬអារម្មណ៍ភាន់ច្រឡំ ។
- មានអារម្មណ៍ភ័យព្រួយ ខ្លាចគ្មាននរណាម្នាក់ជឿសម្ដីរបស់ខ្លួន ។
- គិតថាការរំលោភបំពាន គឺជាកំហុសរបស់ខ្លួនឯង។
- មិនដឹងថាអំពើរំលោភបំពាននោះជារឿងខុសឆ្គង ។
- រងការគំរាមកំហែង ការទិញទឹកចិត្ត ឬត្រូវបានបញ្ចុះបញ្ចូលដោយជនល្មើស ។
- ចង់ការពារជនល្មើស ជាពិសេសប្រសិនបើជនល្មើសនោះជាសមាជិកគ្រួសាររបស់ពួកគេ ជាសាច់ញាតិ ជាមិត្តប្រុស ឬមិត្តស្រីរបស់ខ្លួនជាដើម ។
- ចង់ការពារសុវត្ថិភាពក្រុមគ្រួសារ កេរ្តិ៍ឈ្មោះ ឬសេដ្ឋកិច្ចគ្រួសាររបស់ពួកគេជាដើម ។

ការប្រាប់សាច់រឿងជាលើកដំបូងរបស់កុមារ ភាគច្រើនសុទ្ធតែជាការពិត ។ ប្រសិនបើនៅពេលក្រោយមកទៀត កុមារបានផ្លាស់ប្ដូរសាច់រឿងរបស់ខ្លួន ឬលើកឡើងថាខ្លួនមិនបានទទួលរងការរំលោភបំពានទេ មិនមែនមានន័យថាពួកគេនិយាយកុហកនោះទេ ។

## កុមារអាចផ្លាស់ប្ដូរសាច់រឿងរបស់ពួកគេដោយសារតែ៖

- ទទួលរងសម្ពាធ ឬមិនទទួលបានការគាំទ្រគ្រប់គ្រាន់ ។
- មានអារម្មណ៍ភ័យខ្លាចពីអ្វីដែលនឹងកើតឡើងបន្ទាប់ ឬ ការផ្លាស់ប្ដូរក្នុងជីវិតរបស់ពួកគេ ។
- មានអារម្មណ៍ថាជាការទទួលខុសត្រូវរបស់ខ្លួនឯង ចំពោះលទ្ធផលដែលកើតចេញពីអ្វីដែលខ្លួនបានទម្លាយចេញ ។
- មានហេតុផលផ្សេងៗជាច្រើនទៀត ។

## ជំហានទី២ ឆ្លើយតប និងធ្វើសកម្មភាព

របៀបដែលអ្នកធ្វើការឆ្លើយតប នៅពេលដែលកុមារប្រាប់អ្នកពីការរំលោភបំពាន ឬស្វែងរកជំនួយពីអ្នក ពិតជាមានសារៈសំខាន់ណាស់សម្រាប់ពួកគេ ក្នុងការទទួលបានអារម្មណ៍សុវត្ថិភាព ។ ការបង្ហាញប្រតិកម្មរបស់អ្នកទៅកាន់ពួកគេ អាចឱ្យពួកគេមានអារម្មណ៍ថាទទួលបានការជឿជាក់ ឬទទួលបានការការពារ ឬអាចឱ្យពួកគេទទួលបានអារម្មណ៍កាន់តែភ័យខ្លាច និងឯកាជាងមុន ។

**សូមធ្វើចិត្តឱ្យត្រជាក់ ហើយផ្តល់ការឆ្លើយតបបែបគាំទ្រ អាចធ្វើឱ្យកុមារកាន់តែជឿទុកចិត្តលើអ្នក និងស្វែងរកការគាំទ្រពីអ្នកនៅពេលក្រោយទៀត ។**

រក្សាចិត្តឱ្យត្រជាក់ ជៀសវាងការប្រើកំហឹង ស្តីបន្ទោស ឬស្រែកគំហក ។

ស្តាប់ដោយយកចិត្តទុកដាក់ សូមទុកឱ្យកុមារពន្យល់ពីអ្វីដែលបានកើតឡើងតាមរយៈពាក្យពេចន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងជៀសវាងការបង្ខំពួកគេឱ្យនិយាយ ។

ប្រាប់ពួកគេថាអ្វីដែលបានកើតឡើងមិនមែនជាកំហុសរបស់ពួកគេនោះទេ ហើយវាជារឿងត្រឹមត្រូវហើយដែលពួកគេប្រាប់អំពីរឿងដែលបានកើតឡើងដល់អ្នក ។

ស្វែងរកជំនួយសេវាសុខភាព សម្រាប់កុមារភ្លាមៗ បើទោះបីជាអ្នកមើលទៅពួកគេមិនមាន របួសក៏ដោយ ។

ប្រសិនបើមានសុវត្ថិភាព សូមរក្សាទុកភស្តុតាង ដូចជាសារឆ្លើយឆ្លង(ឆាត) នៅក្នុងទូរស័ព្ទដៃ សម្លៀកបំពាក់ រូបភាព វីដេអូ និងសាក្សីដែលដឹងរឿងជាដើម ។

នៅពេលដែលមានសុវត្ថិភាពភ្លាម សូមទាក់ទងទៅកាន់អាជ្ញាធរ និង/ឬ អង្គការមិនមែនរដ្ឋាភិបាលណាមួយ អ្នកអាចទាក់ទងមកកាន់ អង្គការលីកាដូ តាមរយៈព័ត៌មានលម្អិតខាងក្រោម ។

ពន្យល់ ប្រាប់ពួកគេ អំពីរបៀបដែលអ្នកនឹងថែរក្សាសុវត្ថិភាពរបស់ពួកគេ សិទ្ធិរបស់ពួកគេ និងការរំពឹងទុកនាពេលខាងមុខ ។ ជៀសវាងការសន្យានូវអ្វីដែលអ្នកមិនអាចធ្វើបាន ដូចជា មិនប្រាប់នរណាម្នាក់ អំពីរឿងដែលបានកើតឡើង ប្រសិនបើការប្រាប់ទៅអ្នកណាម្នាក់ ជារឿងចាំបាច់ដើម្បីរក្សាសុវត្ថិភាពរបស់ពួកគេ ។

ការពារ កុមារពីគ្រោះថ្នាក់បន្ថែមទៀតនៅពេលអនាគត ។ សូមអនុវត្តជំហានសុវត្ថិភាពផ្សេងៗ ដើម្បីធានាថាជនល្មើស នឹងមិនអាចទាក់ទងមកពួកគេបន្តទៀត ។

# ជំហានទី៣ ការពារពីគ្រោះថ្នាក់ផ្សេងៗ

**ផ្តល់អាទិភាពដល់សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ បើទោះបីជា ជនល្មើស គឺជាមនុស្សដែលអ្នកបានស្គាល់ ឬជឿទុកចិត្តក៏ដោយ ។ ជាការពិត ជនល្មើស មិនគួរមាន ទំនាក់ទំនងជាមួយកុមារបន្តទៀតទេ ហើយក៏មិនគួរនៅម្នាក់ឯងជាមួយកុមារផ្សេងទៀតឡើយ ។**

ជនល្មើសភាគច្រើន ជាមនុស្សដែលស្គាល់កុមារ រួមមានសមាជិកគ្រួសាររបស់ពួកគេ សាច់ញាតិ មិត្តប្រុស មិត្តស្រី អ្នកជិតខាង គូកន ឬអ្នកដែលរស់នៅក្នុងសហគមន៍ជាមួយកុមារជាដើម ។

កុមារ និងក្មេងជំទង់ត្រូវតែទទួលបានការការពារពីគ្រោះថ្នាក់ផ្សេងៗទោះបីជាពេលខ្លះការធ្វើបែបនេះអាចប៉ះពាល់ដល់ទំនាក់ទំនង ឬកេរ្តិ៍ឈ្មោះក្នុងគ្រួសារឬសហគមន៍ក៏ដោយ។ ជាពិសេសមិនត្រូវឱ្យកុមាររងគ្រោះរៀបការជាមួយជនល្មើសដែលបានប្រព្រឹត្តអំពើហិង្សាផ្លូវភេទជាដាច់ខាត ។

## ទាំងនេះជាជម្រើស ដែលអ្នកអាចពិចារណាដើម្បីការពារកុមារ

**ជម្រើសទី១**

ជាជម្រើសល្អបំផុត ជនល្មើសគួរតែត្រូវបាននាំយកចេញពីផ្ទះដែលកុមារកំពុងរស់នៅ ឬចាកចេញពីសហគមន៍ ដោយមានការគាំទ្រពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈដីការក្សាការពារ ឬដីកាបង្គាប់ឱ្យចាប់ខ្លួនឬដីកាឃុំខ្លួនបណ្ដោះអាសន្ន ។

**ជម្រើសទី២**

ពិចារណាថាតើអ្នកនិងកូនរបស់អ្នក អាចផ្លាស់ទីទៅរកកន្លែងសុវត្ថិភាពណាមួយ ។ អ្នកអាចចូលទៅមើល **គន្លឹះសុវត្ថិភាពរបស់អង្គការលីកាដូ** ប្រសិនបើអ្នកកំពុងទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ហើយពិចារណាក្នុងការចាកចេញពីទីនោះ ។ សុខុមាលភាពផ្លូវចិត្តកុមារ នឹងមានភាពល្អប្រសើរនៅពេលដែលកុមារស្ថិតក្នុងផ្ទះដែលមានសុវត្ថិភាព បើទោះបីជាឪពុកម្ដាយរបស់ពួកគេរស់នៅបែកគ្នាក៏ដោយ ។

**ជម្រើសទី៣**

ប្រសិនបើជម្រើសខាងលើមិនអាចអនុវត្តបានភ្លាម អ្នកអាចពិចារណាក្នុងការបញ្ជូនកុមារទៅរស់នៅកន្លែងដែលមានសុវត្ថិភាព ដូចជាផ្ទះសាច់ញាតិដែលអ្នកទុកចិត្តបំផុត ។

**ជម្រើសទី៤**

មណ្ឌលថែទាំកុមារគួរស្ថិតនៅក្នុងជម្រើសចុងក្រោយ ប្រសិនបើអ្នកមិនអាចស្វែងរកទីកន្លែងសុវត្ថិភាពសម្រាប់កុមារជាមួយសាច់ញាតិបាន ។ ជម្រកសុវត្ថិភាព ឬមណ្ឌលថែទាំកុមារផ្សេងៗ អាចជាតម្រូវការចាំបាច់បណ្ដោះអាសន្ន ដើម្បីសុវត្ថិភាពរបស់កុមារ ។

# ជំហានទី៤ ស្វែងយល់អំពីការផ្លាស់ប្ដូរអាកប្បកិរិយា

កុមារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពាន មានផលប៉ះពាល់ដល់សុខភាពផ្លូវកាយ សុខុមាលភាពផ្លូវចិត្ត និងការអភិវឌ្ឍរបស់កុមារក្នុងរយៈពេលវែង និងស្មុគស្មាញ បើទោះបីជាពួកគេលែងទទួលរងគ្រោះថ្នាក់បន្តទៀតក៏ដោយ ។ កុមារដែលមើលឃើញនូវអំពើហិង្សាក្នុងគ្រួសារ ក៏អាចរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរស្រដៀងគ្នានេះផងដែរ ។

**វាជារឿងធម្មតាសម្រាប់កុមារដែលមានការផ្លាស់ប្ដូរអារម្មណ៍ និងអាកប្បកិរិយាផ្សេងៗគ្នា បន្ទាប់ពីរងការរំលោភបំពាន ។ វាក៏ជារឿងធម្មតាដែរ ប្រសិនបើអ្នកមិនអាចកត់សម្គាល់ឃើញការផ្លាស់ប្ដូរណាមួយរបស់កុមារ ។ ការយល់ថាការឆ្លើយតបរបស់ពួកគេ ទៅលើបញ្ហានេះ គឺជារឿងធម្មតា អាចជួយអ្នកឱ្យបង្ហាញការអាណិតអាសូរ និងការអត់ធ្មត់ទៅកាន់ពួកគេ ។**

## អាកប្បកិរិយាដែលកុមារ ឬក្មេងជំទង់ អាចបង្ហាញទៅកាន់អ្នកមាន

- ហាក់ដូចជាក្រៀមក្រំ អស់កម្លាំង ព្រងើយកន្តើយ ភ័យខ្លាច ឬចូលចិត្តនៅម្នាក់ឯង ។
- មានអារម្មណ៍ឆាប់ខឹង ច្រឡោត ឬបោកប្រាស់របស់របរក្នុងផ្ទះ ។
- មានការលំបាកក្នុងការអនុវត្តអ្វីដែលខ្លួនតែងតែធ្វើជាប្រចាំដូចជា ការសិក្សា ការធ្វើការងារផ្ទះ ការផ្ដោតអារម្មណ៍ ឬការចងចាំនានា ។
- ផ្លាស់ប្ដូរទម្លាប់នៃការញ៉ាំ ការគេង ឬទម្លាប់អនាម័យ សុបិន្តអាក្រក់ ឬគេងនោមដាក់គ្រែ ។
- ភ័យខ្លាច ឬគេចវេសពីស្ថានភាពជាក់លាក់ ទីកន្លែង មនុស្ស ឬវត្ថុមួយចំនួន ។
- មានភាពសកម្មខុសពីធម្មតា ដូចជាភ្ញាក់ៗ រពើរវាយ ឬព្យាយាមធ្វើខ្លួនរវល់ជានិច្ច ។
- ចង់បានការយកចិត្តទុកដាក់ និងក្ដីស្រឡាញ់ពីអ្នកកាន់តែច្រើនជាងមុន ឬតិចជាងមុន ។
- ជៀសវាងទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួន ឬមានជម្លោះច្រើនជាមួយអ្នកដទៃ ។
- មានអារម្មណ៍មិនស្រួលខ្លួន ដូចជាឈឺក្រពះ ឬឈឺក្បាល ។

## ជំហានទី៥ ផ្តល់ការថែទាំយូរអង្វែង

កុមារ និងក្មេងជំទង់ ដែលរងនូវអំពើហិង្សាអាចមានផលប៉ះពាល់ក្នុងរយៈពេលវែង ដូចនេះការបន្តការគាំទ្ររបស់អ្នក អាចជួយព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេឱ្យមានភាពប្រសើរឡើងវិញ ។

### អ្វីដែលអ្នកគួរធ្វើ៖

- បង្ហាញការ**អាណិតអាសូរ** និង**អត់ធ្មត់ចំពោះអារម្មណ៍** និងអាកប្បកិរិយារបស់កុមារ ។
- **ផ្តល់ការគាំទ្រផ្លូវចិត្ត**ដោយសាកសួរសុខទុក្ខពួកគេ ស្តាប់នៅពេលពួកគេចង់ចែករំលែករឿងអ្វីមួយ សាកសួរថាពួកគេត្រូវការអ្វីដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងត្រូវប្រាប់ពួកគេថា វាជារឿងត្រឹមត្រូវហើយដែលពួកគេមានអារម្មណ៍បែបនេះ ។
- រក្សាទម្លាប់ទៀងទាត់ និងដែលអ្នកអាចស្មានដឹងបាន ដូចជាការញ៉ាំអាហារ ទៅសាលារៀន ម៉ោងចូលគេង ការធ្វើកិច្ចការផ្ទះ។ល។ ចំណាយពេលធ្វើសកម្មភាពនានាជាមួយកុមារដែលធ្វើឱ្យពួកគេសប្បាយចិត្ត ។
- សួរកុមារអំពីការទំនាក់ទំនងរាងកាយ ដែលពួកគេមានអារម្មណ៍សុវត្ថិភាពជាមួយ ។ សូម្បីតែការប៉ះពាល់រាងកាយ ដែលជាទូទៅចាត់ទុកថាជាការថ្នាក់ថ្នម ឬលេងសើច ដូចជាការឱបការថើប ការចាក់ក្រឡេចឱ្យសើប ការលើកឡើងលើឱ្យខ្ពស់ ។ល។ ដោយមនុស្សដែលជិតស្និទ្ធជាមួយកុមារ ក៏អាចធ្វើឱ្យកុមារមានអារម្មណ៍ថាគ្មានសុវត្ថិភាពដែរ ។
- ពន្យល់កុមារអំពីអ្វីដែលពួកគេអាចនឹងជួប អំឡុងពេលប្រាស្រ័យទាក់ទងជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រ អាជ្ញាធរ ឬតុលាការ ។ អង្គការមិនមែនរដ្ឋាភិបាលអាចជួយក្នុងរឿងនេះបាន ។
- ប្រសិនបើអាចធ្វើបាន សូមផ្តល់បរិយាកាសកន្លែងរស់នៅ ដែលធ្វើឱ្យកុមារមានអារម្មណ៍ថាមានសុវត្ថិភាព ផាសុកភាព និងមានអ្នកយកចិត្តទុកដាក់ ។

### អ្វីដែលអ្នកមិនគួរធ្វើ៖

- ប្រើប្រាស់ **អំពើហិង្សា ដាក់ទណ្ឌកម្ម ឬស្តីបន្ទោស ។**
- **សួរសំណួរដែលមិនចាំបាច់** ឬការនិយាយដដែលៗនៅក្បែរពួកគេ អំពីហេតុការណ៍លម្អិត ដែលបានកើតឡើង ។
- **ដាក់សម្ពាធ** ពួកគេឱ្យនិយាយ កុមារមិនគួរត្រូវបានគេសួរសំណួរ ឬឱ្យឆ្លើយប្រាប់ពីអ្វីដែលបានកើតឡើងលើពួកគេទៅកាន់មនុស្សជុំវិញខ្លួន ឬអ្នករស់នៅក្នុងសហគមន៍ជាមួយគ្នាដែលមិនចាំបាច់ត្រូវដឹងពីរឿងនោះទេ ។


**ព័ត៌មានទំនាក់ទំនង**

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
តាមរយៈលេខ: **០១២ ៩៣៦ ៣០០ ឬ ០១៥ ៩៥៣ ៨៥៥**

សម្រាប់ព័ត៌មានបន្ថែម និងប្រភព សូមចូលទៅកាន់គេហទំព័រ
**សុវត្ថិភាព និងយុត្តិធម៌**
www.licadho-cambodia.org/safety-and-justice


លីកាដូ LICADHO

២០២៥